# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ ០៥៧/០៩ គ.ជ.ប**

## សេចក្តីណែនាំ

## ស្តីពី

## ការសុំច្បាប់ឈប់ពិសេស សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ឆ្នាំ ២០០៩

**យោង ៖**

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ឆ្នាំ ២០០៩
- សេចក្តីសម្រេចលេខ ១០៥/០០១/២០០៩ កបធ.ច ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ណែនាំដល់លោក លោកស្រីប្រធានគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោតអំពី ការសុំច្បាប់ឈប់ពិសេសសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ឆ្នាំ២០០៩ ដូចខាងក្រោមនេះ ៖

១- បទប្បញ្ញត្តិនៃមាត្រា ១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានបកស្រាយថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលកំពុងបំពេញមុខងារជាសកម្ម គ្មានសិទ្ធិជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបានទេ មានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និងយោធា មិនអាចធ្វើការងាររបស់ខ្លួនផង និងជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផងបានទេ ។ ពាក្យថា "មន្ត្រីរាជការស៊ីវិល" រួមមាន មន្ត្រីរាជការក្នុងក្របខណ្ឌនីតិបញ្ញត្តិ ក្របខណ្ឌនីតិប្រតិបត្តិ ក្របខណ្ឌតុលាការ និងក្របខណ្ឌពិសេសផ្សេងទៀត ។

- តាមស្មារតីនៃមាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ អាចឈរឈ្មោះឲ្យគេបោះឆ្នោត ។ បទប្បញ្ញត្តិបន្ថយសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌពុំបានហាមឃាត់ដាច់ខាតមិនឲ្យឈរឈ្មោះឲ្យគេបោះឆ្នោតនោះទេ ។ ប្រសិនបើមន្ត្រីរាជការស៊ីវិល និងយោធាទាំងនោះ មានបំណងចង់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សាមីខ្លួនត្រូវតែបំពេញលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់នេះ ។

- បទប្បញ្ញត្តិនៃមាត្រា ១៨ ដែលចែកជា ៣ វាក្យខណ្ឌត្រូវបានបកស្រាយដូចខាងក្រោមនេះ ៖

ក/- បទប្បញ្ញត្តិនៃវាក្យខណ្ឌទី ១ មានន័យថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាង

តិចប្រាំពីរ (០៧)ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។ ពាក្យថា "ដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ (០៧)ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ" មានន័យថា ដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារតែប៉ុណ្ណោះ មិនមែនមានន័យថា ដាក់ពាក្យលាលែងពីមុខងារ ឬពីមុខតំណែងឡើយ ។ បទប្បញ្ញត្តិមានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និងយោធាដែលចង់ស្នើជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវសុំការអនុញ្ញាតអវត្តមានពីការងារក្នុងរយៈពេលដូចបានកំណត់ខាងលើ ។

ខ/- បទប្បញ្ញត្តិនៃវាក្យខណ្ឌទី ២ មានន័យថា សាមីខ្លួនជាប់ឆ្នោត ត្រូវធ្វើពាក្យទៅក្រសួង ឬស្ថាប័នរបស់ខ្លួន សុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សាតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងរយៈពេលនៃអាណត្តិនោះ សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬឋានន្តរសក្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ទៀតផង ។

ប្រសិនបើបេក្ខជនជាប់ឆ្នោតហើយ ហើយគ្មានបំណងចង់នៅបម្រើការងារជាសមាជិកក្រុមប្រឹក្សាទេនោះ សាមីខ្លួនត្រូវធ្វើពាក្យទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីសុំដកបេក្ខភាពរបស់ខ្លួនចេញពីបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ ក្នុងករណីនេះ សាមីខ្លួនអាចមកកាន់ការងារដើមរបស់ខ្លួនវិញបាន ។

គ/- បទប្បញ្ញត្តិនៃវាក្យខណ្ឌទី ៣ មានន័យថា នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនអាចត្រឡប់មកបម្រើការងារនៅក្រសួង ឬស្ថាប័នដើមរបស់ខ្លួនវិញបាន ប៉ុន្តែសាមីខ្លួននឹងអាចបានទទួលមុខងារ ឬមុខតំណែងដើមរបស់ខ្លួនវិញបាននោះ គឺអាស្រ័យដោយក្រសួង ឬស្ថាប័នជាអ្នកសម្រេច មិនមែនសាមីខ្លួនអាចទទួលមុខងារ ឬមុខតំណែងដើមរបស់ខ្លួនវិញ ដោយស្វ័យប្រវត្តិនោះឡើយ ។

២- សេចក្តីណែនាំណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីណែនាំនេះ ត្រូវទុកជានិរាករណ៍ ។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត យកចិត្តទុកដាក់ផ្សព្វផ្សាយ និងអនុវត្តឲ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ ២០០៩

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម_សួស្ដី

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
- គណបក្សនយោបាយ
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ